**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/១/០៧-០៩-២០០៩-អវតក/កសចស(អបជ៥៩)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ:**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:** សាធារណៈ:/Public

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ(សំអាងហេតុ)***

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
**ទាំងអស់ក្នុងសំណុំរឿង០០៤/១**

**សហមេធាវី អ៊ឹម ចែម:**
ប៊ិត ស៊ាងលឹម
Wayne JORDASH

## I. ការឆ្លើយតប

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") សូមធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម[1] (ចម្លើយតប) ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ សពអ[2] ("បណ្ដឹងឧទ្ធរណ៍") ប្រឆាំងនឹង*ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត* ("សចស") *លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយនិងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ*[3]("ដីកាសម្រេចដែលរងការជំទាស់")។

2. អ៊ឹម ចែម ចាប់ផ្ដើមចម្លើយតបរបស់ខ្លួនដោយតវ៉ាថា បណ្ដឹងឧទ្ធរណ៍គ្មានភាពជាក់លាក់គ្រប់គ្រាន់សម្រាប់ឲ្យគាត់អាចធ្វើការឆ្លើយតបបាន[4] ដែលជាការទាមទារមួយមានលក្ខណៈភូតភរដោយសារផ្អែកនៅសល់ទាំងប៉ុន្មាននៃសារណារបស់គាត់ បានធ្វើការកំណត់អត្តសញ្ញាណអំណះអំណាងរបស់សពអ ដែលបានដាក់ជូន។ សូម្បីតែសេចក្ដីយោងទៅរកបទដ្ឋានតែមួយគាត់ដែល អ៊ឹម ចែម[5] បានពឹងផ្អែក ក៏គ្មានចំណោទសមហេតុផលណាមួយដែលថា បណ្ដឹងឧទ្ធរណ៍ "កំណត់អត្តសញ្ញាណពីបញ្ហានានាដែលកំពុងមានជម្លោះនោះមានការយោងទៅរករបកគំហើញជាក់លាក់ណាមួយ"[6] របស់សចស ដែរ។ បណ្ដឹងឧទ្ធរណ៍អនុវត្តទាំងស្រុងទៅតាមបទដ្ឋានដែលបានកំណត់ដោយអង្គជំនុំជម្រះ

---

1 **D309/2/1/3** ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)*, ៤ កញ្ញា ២០១៧ (ចាប់ពីនេះតទៅហៅថា "ចម្លើយតប")។

2 **D309/2/1/2** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប*ដីកាដំណោះស្រាយ(សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ*ដីកាដំណោះស្រាយ (សម្អាងហេតុ)*, ៩ សីហា ២០១៧ (ចាប់ពីនេះតទៅហៅថា "បណ្ដឹងឧទ្ធរណ៍")។

3 **D309/2** ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ, ១០ កក្កដា ២០១៧ (ចាប់ពីនេះតទៅហៅថា "ដីកាសម្រេចដែលរងការជំទាស់")។

4 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ២២-២៨។

5 **D309/2/1/3** ចម្លើយតប, កំណត់សំគាល់ជើងទំព័រ ២១ *ដកស្រង់* សំណុំរឿង**០០១-F28** សាលដីកាលើបណ្ដឹងសាទុក្ខ, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៤១។

6 **D309/2/1/3** ចម្លើយតប, កំណត់សំគាល់ជើងទំព័រ ២១ *ដកស្រង់* សំណុំរឿង**០០១-F28** សាលដីកាលើបណ្ដឹងសាទុក្ខ, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៤១។

តុលាការកំពូលដែលថា អ៊ឹម ចែម លើកយោង[7] ព្រមទាំងលក្ខខណ្ឌតម្រូវនៃវិធាន៧៥(២) ផងថា "ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និង អង្គច្បាប់ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍"[8]។

3. បណ្តឹងឧទ្ធរណ៍បង្ហាញអំពីកំហុសអង្គច្បាប់យ៉ាងច្បាស់លាស់ (ខុសពីបទដ្ឋាននៃការរំលោភបំពានឆន្ទានុសិទ្ធិដែល អ៊ឹម ចែម ពេញចិត្ត)។ នេះគឺជាភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ក្រឡែតចេញពីបណ្តឹងឧទ្ធរណ៍ទាំងមូលដែលតវ៉ាយ៉ាងច្បាស់ថា "ច្បាប់ និងគោលការណ៍ពាក់ព័ន្ធនានា **តម្រូវឱ្យ**ដាក់ *ដីកាដំណោះស្រាយ(សំអាងហេតុ)* ជាសាធារណៈទាំងស្រុង"[9]។ បណ្តឹងឧទ្ធរណ៍បានពឹងផ្អែកយ៉ាងលេចធ្លោទៅលើពាក្យពេចន៍ចាប់បង្ខំនៃវិធាន២១ ដែលចែងត្រង់ផ្នែកដែលពាក់ព័ន្ធ៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលជាធរមានទាំងអស់ **ត្រូវ** បកស្រាយក្នុងន័យ... ដើម្បីធានា... កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[10] និង "អង្គជំនុំជម្រះវិសាមញ្ញ **ត្រូវ** ធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន"[11]។ នៅក្នុងបទប្បញ្ញត្តិទាំងនេះនៃច្បាប់ អ.វ.ត.ក មិនមាននិយាយអ្វីទាក់ទងនឹងឆន្ទានុសិទ្ធិទេ ដោយហេតុថា បទប្បញ្ញត្តិទាំងនេះប្រើពាក្យថា "**ត្រូវ**" ដែលមានន័យយ៉ាងច្បាស់ថាចាប់បង្ខំ។

4. ទោះបីជាមានអាណត្តិច្បាស់លាស់នៃច្បាប់ អ.វ.ត.ក និងករណីយុត្តិសាស្ត្រអន្តរជាតិ ទាក់ទងនឹងតម្លាភាពក៏ដោយ ក៏ អ៊ឹម ចែម នៅតែតវ៉ាថា "ការកោសលុប គឺសេចក្តីសម្រេចមានលក្ខណៈជាឆន្ទានុសិទ្ធិ"[12] និងថាបើដូច្នេះ ការរំលោភបំពានឆន្ទានុសិទ្ធិ គឺជាបទដ្ឋានត្រួតពិនិត្យសមស្រប"[13]។ ប៉ុន្តែដើម្បីគាំទ្រដល់ការតវ៉ានេះ អ៊ឹម ចែម ត្រូវបង្ខំចិត្តជ្រើសរើសយកករណីយុត្តិសាស្ត្រមិនពាក់ព័ន្ធ

---

7 **D309/2/1/3** ចម្លើយតប, កំណត់សំគាល់ជើងទំព័រ ២១ *ដកស្រង់* សំណុំរឿង០០១-**F28** សាលដីកាលើបណ្តឹងសាទុក្ខ, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៤១។

8 វិធាន ៧៥(២) នៃវិធានផ្ទៃក្នុង។ បណ្តឹងឧទ្ធរណ៍ក៏អនុវត្តតាមយ៉ាងពេញលេញចំពោះសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៨, មាត្រា ៤.១, តាមរយៈការផ្តល់នូវ "អំណះអំអាងផ្លូវច្បាប់យ៉ាងលម្អិត"។

9 **D309/2/1/2** ចម្លើយតប, វាក្យខណ្ឌ IV(ក) (សង្កត់ន័យដើម)។

10 វិធាន ២១(១) នៃវិធានផ្ទៃក្នុង (សង្កត់ន័យដើម)។

11 វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង (សង្កត់ន័យដើម)។

12 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ២៤។

13 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ២៤។

មកដោះស្រាយលើសេចក្តីសម្រេចទាក់ទងនឹងភាពសម្ងាត់ **នៅក្នុងអំឡុងពេល** នៃកិច្ចស៊ើបសួរទៅវិញ[14] ដែលត្រង់ចំណុចនេះតក្កភាពគឺថា សចស តម្រូវឱ្យមានឆន្ទានុសិទ្ធិមួយចំនួនជាក់លាក់ទៅលើភាពសម្ងាត់នៃព័ត៌មាន ដើម្បីធានាថា កិច្ចស៊ើបសួរនឹងមិនត្រូវបានសម្របសម្រួលនោះឡើយ។ យ៉ាងណាមិញ ដូចបានកត់សំគាល់នៅក្នុងបណ្តឹងឧទ្ធរណ៍ ក្នុងពេលនៃដីកាដំណោះស្រាយ មុខងារនៃកិច្ចស៊ើបសួរ ផ្តល់យុត្តិកម្មថាឆន្ទានុសិទ្ធិនោះត្រូវបានបញ្ឈប់។

5. អំណះអំណាងរបស់ អ៊ឹម ចែម ដែលថា ការកោសលុប*ដីកាដំណោះស្រាយ(សំអាងហេតុ)* "ធ្វើឱ្យមានតុល្យភាពត្រឹមត្រូវរវាងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានការជូនព័ត៌មាន ភាពសម្ងាត់នៃកិច្ចស៊ើបសួរ និងសិទ្ធិរបស់ជនសង្ស័យ"[15]នោះ គឺគ្រាន់តែជាការថាឡើងវិញអំពីការភាន់ច្រឡំរបស់ សចស នៅក្នុងដីកាសម្រេចដែលរងការជំទាស់ប៉ុណ្ណោះ។ តាមពិត នៅក្នុងការព្យាយាមមួយដើម្បីទាញថយក្រោយនៃការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូល ("អជតក") ចំពោះ "តម្រូវការនៃតម្លាភាពដែលយកចេញពីគោលការណ៍ជាមូលដ្ឋាន ដែលគ្រប់គ្រងទៅលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ស្របតាមស្មារតីនៃគោលបំណងសម្រាប់ការអប់រំ និងកេរ្តិ៍ដំណែលរបស់តុលាការនេះ"[16] អ៊ឹម ចែម មិនបានបង្អុលពីយុត្តិសាស្ត្រទប់ទល់របស់ អជតក ឬ អង្គជំនុំជម្រះនេះទេ ប៉ុន្តែផ្ទុយមកវិញ គាត់លើកយោងទៅរក សចស ជាថ្មីម្តងទៀត[17]- ដែលជាប្រភពតែមួយគត់ដែលបានបង្កើតឱ្យមានដីកាសម្រេចដែលរងការជំទាស់ - និងបន្ទាប់មក ទៅរកសេចក្តីសម្រេចមួយពាក់ព័ន្ធនឹងការបំពារបំពាននៃភាពសម្ងាត់នៃសេចក្តីសម្រេចនានាដែលលើកអំពី "ការអភិវឌ្ឍន៍នីតិវិធីក្នុងរឿងក្តីជាក់លាក់មួយ" ដែល "កើតឡើងនៅក្នុងផ្នែកសម្ងាត់នៃកិច្ចដំណើរការនីតិវិធី"[18]។

---

[14] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ២៤ (ដកស្រង់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ អោ អាន ដែលកំពុងធ្វើ)។ *ដដែលដូចខាងលើ*, កថាខណ្ឌ ២៥ (ដកស្រង់ដីកាសម្រេចរបស់សហចៅក្រមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ យឹម ទិត្យ ដែលកំពុងធ្វើ)។

[15] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ២៩។

[16] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៣១ *ដកស្រង់* សំណុំរឿង០០១-**F30/2** សេចក្តីសម្រេចលើគោលការណ៍នៃនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង, ២៦ កក្កដា ២០១២, កថាខណ្ឌ ៥។

[17] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៣២។

[18] សំណុំរឿង០០៤-**D355/9** ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ, ១១ សីហា ២០១៧, កថាខណ្ឌ ១២។

6. បើមិនលើស ក៏ស្រដៀងគ្នាដែរ គឺអ្វីដែលមិនមានលក្ខណៈអន្ទងនោះគឺការព្យាយាមរបស់ អ៊ឹម ចែម ដើម្បីពឹងផ្អែកលើរឿងក្ដីមួយនៅតុលាការសិទ្ធិមនុស្សអឺរ៉ុប(“ECtHR”)ដើម្បីធ្វើជាមូលដ្ឋាន គឺរឿងក្ដី *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ* ដើម្បីជាការគាំទ្រដល់អំណះអំណាងរបស់គាត់[19]។ ក្នុងរឿងក្ដី *Welke* នេះ តុលាការ ECtHR បានសម្រេចថា គេអាចអនុញ្ញាតឲ្យតែចំណែកមួយនៃសាលក្រមទៅជាសាធារណៈ នៅក្នុងកាលៈទេសៈជាក់លាក់[20]តែប៉ុណ្ណោះ ត្រង់ចំណុចណាដែលមាន “តម្រូវការចាំបាច់ដើម្បីរក្សាការសម្ងាត់ចំពោះវិធីសាស្ត្រនៃកិច្ចស៊ើបសួររបស់នគរបាលដែលបានប្រើប្រាស់”[21] ហើយភស្តុតាងដាក់ចំណាត់ថ្នាក់សម្ងាត់យ៉ាងទូលំទូលាយ ត្រូវបានស្ដាប់សវនាការដោយតុលាការ *ជាអសាធារណៈ*[22] រួចហើយ។ ផ្ទុយទៅវិញ គេគ្មានមូលហេតុជាយុត្តិកម្មដើម្បីរក្សាមួយផ្នែកធំនៃ *ដីកាដំណោះស្រាយ(សំអាងហេតុ)* ជាការកោសលុបទេ។

7. អ៊ឹម ចែម អះអាងថា សពអ នៅក្នុងការលើកពីច្បាប់ក្នុងស្រុកដែលបានលើកឡើងដោយ សចស និងនៅក្នុងការកត់សម្គាល់ថាច្បាប់មិនគាំទ្រដល់គោលជំហររបស់ សចស ទេគឺ “មិនបានកោតសរសើរនូវចំណុចគោលដៅរបស់សហចៅក្រមស៊ើបអង្កេត [sic] ពោលគឺនៅពេល ដែលពួក គាត់បាន លើកឡើងថា ទាំងនេះគឺជាឧទាហរណ៍ដែលចង្អុលបង្ហាញពីលក្ខណៈធម្មតា នៃដីកា សម្រេចរងការជំទាស់”[23]។ យ៉ាងណាក៏ដោយ គឺ អ៊ឹម ចែម ដែលទំនងជាខកខានមើលមិនឃើញពីគុណតម្លៃនៃការពិភាក្សាអំពីបទប្បញ្ញត្តិទាំងនេះនៅក្នុងបណ្ដឹងឧទ្ធរណ៍ ដោយសារវាបានបង្ហាញថាបទប្បញ្ញត្តិទាំងនេះមិនបានលើកឡើងពីគ្រប់កាលៈទេសៈទាំងអស់នៃ*ដីកាដំណោះស្រាយ(សំអាងហេតុ)* ពីព្រោះ ដូចដែលវា បានបញ្ជាក់នៅក្នុងបណ្ដឹងឧទ្ធរណ៍ស្រាប់ហើយថា “១) ពួកវាដោះស្រាយការរក្សាការសម្ងាត់ក្នុង អំឡុងពេលស៊ើបសួរ មិនមែននៅពេលកិច្ចស៊ើបសួរត្រូវបានបញ្ចប់ហើយនោះទេ, និង ២) ពួកវា ទាក់ទងនឹងការដាក់បង្ហាញសម្ភារៈ ដែលមិនត្រូវបានអនុញ្ញាតក្នុងអំឡុងពេលស៊ើបសួរ មិនមែនថា តើអង្គតុលាការគួរចាត់ថ្នាក់សេចក្ដីសម្រេចលើកលែងការចោទប្រកាន់រឿងក្ដីមួយថាជាការសម្ងាត់ ឬយ៉ាងណា”[24]។

---

[19] ECtHR *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ*, សាលក្រម, ១ មីនា ២០១១។

[20] *សូមអាន* ECtHR *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ*, សាលក្រម, ១ មីនា ២០១១, កថាខណ្ឌ ៨៤ (“ដោយមានការគិតគូរអំពីទម្រង់ជាក់លាក់នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌជាចំណោទ្យ…”)។

[21] ECtHR *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ*, សាលក្រម, ១ មីនា ២០១១, កថាខណ្ឌ ៧៧។

[22] ECtHR *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ*, សាលក្រម, ១ មីនា ២០១១, កថាខណ្ឌ ៧៦។

[23] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៣៥។

[24] **D309/2/1/2** បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ៤៨ (សង្កត់ន័យបន្ថែមត្រូវបានរំលងចោល)។

8. អ៊ឹម ចែម មិនពេញចិត្តនឹងបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសស្វីស និងក្រមព្រហ្មទណ្ឌរបស់ប្រទេសអាល្លឺម៉ង់ ដែលអនុញ្ញាតឲ្យមាន "សេចក្តីថ្លែងការណ៍" ជាផ្នែកនៃដីកាបង្គាប់ ឬដីកាសម្រេច (នៅក្នុងករណីក្រមរបស់ប្រទេសបារាំង) ឬមិនតម្រូវឲ្យមាន "សេចក្តីថ្លែងការណ៍" នៅក្នុងករណីលើកលែងការចោទប្រកាន់ (នៅក្នុងករណីក្រមរបស់ប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស) មកគាំទ្រអំណះអំណាងរបស់គាត់[25]។ ប៉ុន្តែ សេចក្តីអះអាងនេះគឺមានមូលដ្ឋាននៅលើ ឬមួយ ការមិនយល់ពីវាក្យស័ព្ទ "សេចក្តីថ្លែងការណ៍" របស់គាត់ ឬមួយ សទិសភាពខុសឆ្គងរវាង "សេចក្តីថ្លែងការណ៍" និង "ធ្វើឲ្យសាធារណជនអាចរកបាន"។ វាជាការច្បាស់លាស់នៅក្នុងបរិបទនៃការប្រើប្រាស់ពាក្យ "សេចក្តីថ្លែងការណ៍"[26] ឬ "ត្រូវបានប្រកាសជាសាធារណៈ"[27] នៅក្នុងការលើកឡើងពីក្រមច្បាប់ ដែលយោងទៅដល់អំពើជារូបវន្តនៃការប្រកាស ឬការចែកចាយ គឺមិនមែនគ្រាន់តែជាដកហូតនូវភាពសម្ងាត់ច្បាប់ប៉ុណ្ណោះទេ។ នៅពេលក្រោយៗមកទៀត អ៊ឹម ចែម បានធ្វើកំហុសដដែលនៃការដាក់បញ្ចូលគ្នានូវពាក្យ "សេចក្តីថ្លែងការណ៍" ជាមួយនឹង "ធ្វើឲ្យសាធារណជនបានដឹងឮ" នៅក្នុងចម្លើយតបរបស់គាត់ នៅពេលដែលគាត់បានលើកឡើងពីការអត្ថាធិប្បាយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង សម្រាប់ជាសេចក្តីស្នើដែលថា សេចក្តីថ្លែងការណ៍នៃដីកាសម្រេចលើកលែងការចោទប្រកាន់ គឺមានគោលបំណងផ្តោះទៅរកការកាត់បន្ថយនៃការចាប់អារម្មណ៍ទៅលើប្រព័ន្ធផ្សព្វផ្សាយ[28]។

9. អ៊ឹម ចែម អះអាងថាវាគឺជាករណីយុត្តិសាស្ត្រថា ការស៊ើបសួរបញ្ចប់តាមផ្លូវការតែប៉ុណ្ណោះកាលណាអង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ណាក៏ដោយ ក្នុងដីកាដំណោះស្រាយ ហើយដូច្នេះ លក្ខខណ្ឌតម្រូវនៃវិធាន៥៦ ស្តីពីភាពសម្ងាត់នៅក្នុងកំឡុងពេលនៃ "ការស៊ើបសួរ" នៅបន្តមានអត្ថិភាព[29]។ ទីមួយ សពអ កត់សម្គាល់ថា រឿងនេះទំនងជាការបានទទួលដឹងឮដោយ អ៊ឹម ចែម ដែលថាយ៉ាងហោចណាស់ក៏នៅក្នុងរយៈពេលនៃការបញ្ចប់បណ្តឹងឧទ្ធរណ៍ពីក្នុង *ដីកាដំណោះស្រាយ(សំអាងហេតុ)* ភាពសម្ងាត់នៅក្រោមវិធាន៥៦ គឺលែងធានាទៀតហើយ

---

25 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៣៥-៣៧។

26 ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង, មាត្រា១៧៧-១, ២១២-១ (សំណៅអង់គ្លេស ឆ្នាំ២០០៦)។

27 ក្រមព្រហ្មទណ្ឌរបស់ប្រទេសអាល្លឺម៉ង់, ផ្នែក១៦៥(១), ២០០(១) (សំណៅអង់គ្លេស ឆ្នាំ២០១០)។

28 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៦០។

29 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៣៩។

ដូច្នេះហើយការកោសលុបគួរត្រូវបានលើកលែង។ ទីពីរ មានប្រភពតែមួយគត់ដែលថា អ៊ឹម ចែម បានលើកឡើងសម្រាប់សេចក្តីសន្និដ្ឋានរបស់គាត់ថា វាជា "ករណីយុត្តិសាស្ត្រ" ដែលថាដំណាក់កាលនៃការស៊ើបសួរ គឺបានបញ្ចប់តែកាលណាបណ្តឹងឧទ្ធរណ៍ពីក្នុងដីកាដំណោះស្រាយដែលត្រូវបានសម្រេច គឺជាសេចក្តីសម្រេចមួយដែលរងការជំទាស់ត្រូវបានប្តឹងជំទាស់នៅក្នុងបណ្តឹងឧទ្ធរណ៍នេះប៉ុណ្ណោះ[30] និងសេចក្តីសម្រេចដែលរងការជំទាស់ខ្លួនវានោះ មិនបានលើកឡើងពីប្រភពច្បាប់សម្រាប់ការកំណត់នេះទេ។ លើសពីនេះទៀត តាមវាក្យស័ព្ទរបស់វា វិធាន៥៦ អនុវត្តចំពោះ "កិច្ចស៊ើបសួរ" តែមិនមែនចំពោះ "ដំណាក់កាលនៃការស៊ើបសួរ" នោះទេ ហើយនៅពេលដែលអំពើស៊ើបសួរលែងត្រូវការធ្វើតទៅទៀតហើយនោះ - ដូចជានៅពេលដែលដីកាដំណោះស្រាយត្រូវបានចេញ - សំអាងហេតុសម្រាប់ភាពសម្ងាត់នៃកិច្ចស៊ើបសួរលែងមានអត្ថិភាពតទៅទៀតហើយ។

10. អ៊ឹម ចែម អះអាងថាវា "មានពិភាល់" ដែលថា សពអ បានកត់សម្គាល់ថា វាជាបទដ្ឋានសម្រាប់ឯកសារដែលត្រូវពិនិត្យឡើងវិញដើម្បីប្រកាសជាចំហរជាអតិបរមានៅទីបញ្ចប់នៃសំណុំរឿងមួយ[31]។ គាត់អះអាងថា ចាប់តាំងពី សចស បានធ្វើការកំណត់រួចជាស្រេចហើយ ពាក់ព័ន្ធនឹងចំណាត់ថ្នាក់នៃ*ដីកាដំណោះស្រាយ(សំអាងហេតុ)* មិនមានការពិនិត្យឡើងវិញណាដែលចាំបាច់នោះទេ និងបានអះអាងថា សពអ គឺបានប៉ុនប៉ង "ជ្រើសរើសយកយុត្តាធិការណាដែលអំណោយផលដល់ខ្លួន" នៅក្នុងការសុំឲ្យ អបជ ពិនិត្យមើលបញ្ហានេះឡើងវិញ[32]។ អំណះអំណាងនេះឆ្លុះបញ្ចាំងពីការយល់ខុសទៅលើការអនុវត្តនីតិវិធីនៅ អ.វ.ត.ក និងវាយតម្លៃទាបនូវតួនាទីសំខាន់ របស់អង្គបុរេជំនុំជម្រះ នៅក្រោមច្បាប់ អ.វ.ត.ក។ ទីមួយ ការប្តឹងឧទ្ធរណ៍មិនមែនជាគំរូនៃ "ការជ្រើសរើសយកយុត្តាធិការណាដែលអំណោយផលដល់ខ្លួន" វាគឺជាការ អនុវត្តនូវសិទ្ធិមួយនៅក្រោមវិធាន។ គឺអង្គបុរេជំនុំជម្រះដែលត្រូវមានការនិយាយស្តីផ្តាច់ព្រ័ត្រ នៅលើបញ្ហានានាដែលនាំយកមកនៅចំពោះមុខខ្លួន ហើយភាគីនានាគឺមិននៅក្រោមកាតព្វកិច្ចទទួលយកការជំនុំជម្រះក្តីដែលខុសឆ្គងដោយ សចស ដោយមិនបានអនុវត្តនូវសិទ្ធិនាំយកបញ្ហានោះទៅ ចំពោះមុខអង្គបុរេជំនុំជម្រះ នោះដែរ។ ទីពីរ សេចក្តីណែនាំអនុវត្តដែលបានលើកឡើងស្តីពីចំណាត់ ថ្នាក់ បានចាត់ចែងយ៉ាងច្បាស់លាស់ថា "ការិយាល័យតុលាការចុងក្រោយដែលទទួលបាន សំណុំរឿង" ត្រូវធ្វើការ

---

30 *សូមអាន* **D309/2/1/3** ចម្លើយតប, កំណត់សម្គាល់ជើងទំព័រទី៥៤។

31 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៣៩។

32 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៣៩។

ពិនិត្យឡើងវិញអំពីចំណាត់ថ្នាក់នេះ[33]។ គឺអង្គបុរេជំនុំជម្រះនេះឯងហើយ ដែលបច្ចុប្បន្ននេះ សំណុំរឿងនេះត្រូវបានប្ដឹង។ មិនមានកាលៈទេសៈណាមួយដែល កសចស ត្រូវតែជាការិយាល័យចុងក្រោយចាប់យកសំណុំរឿងនេះទេ ដូច្នេះហើយការកំណត់របស់ សចស មិនជាស្ថាពរនោះទេ។

11. អ៊ឹម ចែម ដកស្រង់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ការលើកឡើងថា "រាល់សេចក្ដីសម្រេចទាំងឡាយដែលទាក់ទងនឹងការកោសលុប ដីកាសម្រេចនោះត្រូវតែធ្វើការ 'វាយតម្លៃលើអង្គសេចក្ដីម្ដងមួយៗតាមករណីជាក់ស្ដែង' ក្នុងកាលៈទេសៈជាក់លាក់នោះ"[34] និងបានអះអាងថា "គ្មានករណីយុត្តិសាស្ត្រ [អន្តរជាតិ] ណាមួយធ្វើឲ្យខិនថយដល់បញ្ហាជាប់ទាក់ទងនឹងភស្តុតាងជាក់ស្ដែងពាក់ព័ន្ធនឹងសិទ្ធិក្នុងការទទួលបានការសន្មតថាគ្មានទោសហើយនិងសិទ្ធិឯកជនដែលអាចនឹងមានទំនាក់ទំនងកាន់តែរឹងមាំ នៅក្នុងកាលៈទេសៈនៃការលើកលែងការចោទប្រកាន់លើសំណុំរឿងមួយ"[35]។ ប៉ុន្តែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែល អ៊ឹម ចែម បានដកស្រង់នោះ បង្ហាញថា ការកោសលុបដ៏ច្រើនសន្ធឹកសន្ធាប់នៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* មិនមានអង្គសេចក្ដីឡើយ។ កថាខណ្ឌដែលយោងសំអាងនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះ ពិភាក្សាអំពីការកោសលុបឈ្មោះ និងព័ត៌មានផ្សេងទៀតក្នុងគោលបំណងការពារសាក្សី និងជនរងគ្រោះ[36] ហើយបន្ទាប់មកបានសម្រេចថា ការកោសលុបបែបទាំងនោះគួរធ្វើឡើង "តែក្រោយការវាយតម្លៃពីភាពមិនអាចធ្វើបាន ឬភាពគ្រប់

---

33 សេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង, សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/ ០០៤/២០០៩/វិ. លើកទី២, មាត្រា១២.២។

34 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៤៤, *ដកស្រង់* តុលាការ ICC, រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលក្រមលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ I មានចំណងជើងថា "សេចក្ដីសម្រេចបង្កើតគោលការទូទៅដែលគ្របដណ្ដប់លើការអនុវត្តនានាដើម្បីដាក់កម្រិតការដាក់បង្ហាញអនុលោមតាមវិធាន ៨១(២) និង (៤) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាង", ១៣ តុលា ២០០៦, កថាខណ្ឌ ៣៩។

35 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៤៤។

36 តុលាការ ICC, រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលក្រមលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ I មានចំណងជើងថា "សេចក្ដីសម្រេចបង្កើតគោលការទូទៅដែលគ្របដណ្ដប់លើការអនុវត្តនានាដើម្បីដាក់កម្រិតការដាក់បង្ហាញអនុលោមតាមវិធាន ៨១(២) និង (៤) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាង", ១៣ តុលា ២០០៦, កថាខណ្ឌ៣៣។ វិធានស្ដីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICC, វិធាន ៨១ (៤)។

គ្រាន់នៃវិធានការការពារដែលមានលក្ខណៈដាក់កម្រិតតិចជាងតែប៉ុណ្ណោះ"[37]។ ដូចដែល សពអ បានថ្លែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ការកោសលុបសម្រាប់មូលហេតុត្រឹមត្រូវនៃការការពារសាក្សីក្នុង*ដីកាដំណោះស្រាយ (សំអាងហេតុ)* មានលក្ខណៈសមហេតុផល[38]។ ជាងនេះទៀត ដូចដែល សពអ បានពន្យល់ក្នុងបណ្តឹងឧទ្ធរណ៍ តុលាការ ICC ជាទម្លាប់ អនុវត្តជាប្រចាំតែការកោសលុបមានកម្រិតនៃឈ្មោះរបស់សាក្សីប៉ុណ្ណោះ នៅពេលដែលចេញសេចក្តីសម្រេចសាធារណៈនៅដំណាក់កាលបញ្ជាក់ពីការចោទប្រកាន់ សូម្បីតែនៅពេលដែលសេចក្តីសម្រេចទាំងនោះលើកលែងការចោទប្រកាន់ក៏ដោយ។

12. អ៊ឹម ចែម និយាយដដែលៗអំពីដីកាសម្រេចដែលរងការជំទាស់ នៅក្នុងការជជែកថា ដោយសារតែចរិកលក្ខណៈនៃដីកាដំណោះស្រាយជាការលើកលែងការចោទប្រកាន់ ការកោសលុបគឺត្រឹមត្រូវដើម្បីធានាដល់ "សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានជីវិតឯកជន និងការសន្មតថាគ្មានទោស"[39] ក៏ប៉ុន្តែ ដូចទៅនឹងដីកាសម្រេចដែលរងការជំទាស់ដែរ វាខកខានមិនបានបង្ហាញថាការការពាររបស់មាត្រា១៧ នៃកតិកាសញ្ញា ICCPR ប្រឆាំងនឹង "ការជ្រៀតជ្រែក ឬការប៉ះពាល់" ដល់ឯកជនភាពដោយរបៀបណានោះទេ ហើយសិទ្ធិចំពោះសច្ចធារណ៍នៃនិរទោសក៏មិនត្រូវបានពាក់ព័ន្ធតាមរយៈសាធារណជនដែលអាចចូលមើល *ដីកាដំណោះស្រាយ (សំអាងហេតុ)* បានទាំងស្រុងនោះដោយរបៀបណាដែរ។ ដូចដែល សពអ បានដកស្រង់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថាអង្គជំនុំជម្រះនេះបានពន្យល់យ៉ាងសមហេតុសមផលថា កាលណាដីកាមួយត្រូវបាន "ចេញដោយស្ថាប័នតុលាការមានសមត្ថកិច្ចផ្អែកតាមច្បាប់ តាមរយៈដំណើរការតទល់ចំពោះមុខ និងត្រូវបានសម្រេចយ៉ាងសមហេតុផលក្នុងគោលបំណងស្របច្បាប់មួយ គឺក្នុងកិច្ចសហការដើម្បីបំពេញបេសកកម្មស្វែងរកការពិតដោយស្ថាប័នតុលាការមួយផ្សេងនៅ អ.វ.ត.ក។ ដូច្នេះ ដីកាសម្រេចនេះពុំត្រូវបានចេញតាមទំនើងចិត្តឡើយ"[40]។ ហេតុដូច្នេះហើយ ផ្ទុយទៅនឹងការអះអាង

---

[37] តុលាការ ICC, រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I មានចំណងជើងថា "សេចក្តីសម្រេចបង្កើតគោលការទូទៅដែលគ្របដណ្តប់លើការអនុវត្តនានាដើម្បីដាក់កម្រិតការដាក់បង្ហាញអនុលោមតាមវិធាន ៨១(២) និង (៤) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង", ១៣ តុលា ២០០៦, កថាខណ្ឌ៣៧។

[38] **D309/2/1/2** បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ២។

[39] **D309/2/1/3** ចម្លើយតប, ចំណងជើង IV(ឃ)។

[40] **D309/2/1/2** បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ៦០, *សូមផង* សំណុំរឿង០០៣-**D100/32/1/7** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់

របស់ អ៊ឹម ចែម វាមិនមានលក្ខខណ្ឌតម្រូវបន្ថែមទៀត ក្រោមមាត្រា១៧ ដើម្បីកំណត់អ្វីទៅជាការ "សមហេតុផល" នៅក្នុងកាលៈទេសៈនេះ[41]។ ដើម្បីឱ្យដឹងជាក់ច្បាស់ដាច់ខាតនោះ៖ សិទ្ធិឯកជនដែលបានការពារដោយមាត្រា១៧ នឹងមិនត្រូវបានប៉ះពាល់ដោយការបិទទាំងស្រុងនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* នោះទេ។

13. ទាក់ទងនឹងសិទ្ធិចំពោះសច្ចធារណ៍នៃនិរទោស អ៊ឹម ចែម បានធ្វើអំណះអំណាងបែបទាយស្មានអំពីអ្វីដែលប្រព័ន្ធផ្សព្វផ្សាយអាចនិយាយ ប្រសិនបើពួកគេអាចចូលមើល*ដីកាដំណោះស្រាយ (សំអាងហេតុ)* ទាំងមូល[42]។ ការទាយស្មានបែបនេះមិនត្រឹមតែមិនគ្រប់គ្រាន់ដើម្បីរារាំងការចូលមើលជាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែ ដូចដែល អ៊ឹម ចែម ត្រូវបានបង្ខំឱ្យទទួលយកនោះ គោលការណ៍នេះថែមទាំងផ្ដោតផ្ទាល់ទៅលើប្រព័ន្ធផ្សព្វផ្សាយ មិនមែនចំពោះតុលាការនោះទេ[43]។ សូម្បីតែឧទាហរណ៍តែមួយគត់ដែល អ៊ឹម ចែម បានយោងសំអាងទៅលើអត្ថបទព័ត៌មានដែលលើកឡើងថា "លាបពណ៌ទាក់ទាញចិត្តអ្នកអានតាមរយៈការធ្វើនិទានកថាអំពីការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងសកម្មភាពឧក្រិដ្ឋ"[44]នោះ កត់សម្គាល់ជាដដែលៗថា ឧក្រិដ្ឋកម្មទាំងនោះគ្រាន់តែជាការចោទប្រកាន់តែប៉ុណ្ណោះ និងបានដាក់កម្រិតខ្លួនវាក្នុងច្រកមួយដែលជ្រើសរើសដោយ អ៊ឹម ចែម ត្រឹមការដកស្រង់របាយការណ៍សាធារណៈរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) និងសក្ខីកម្មសាធារណៈពីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២[45] តែប៉ុណ្ណោះ។ ហេតុដូច្នេះ ការណ៍នេះប្រហែលជាមិនមែនជាភស្តុតាងនៃ "ការកាត់សេចក្ដីដោយប្រព័ន្ធផ្សព្វផ្សាយ" នោះទេ[46]។

14. វាក៏ជាការភ័យខ្លាចបែបទាយស្មានផងដែរដែលថា ការបញ្ចេញ*ដីការដំណោះស្រាយ (សំអាងហេតុ)* អាច "ទាក់ទាញឱមានការទិតៀនមិនសមហេតុផល និងអយុត្តិធម៌ចំពោះ អ.វ.ត.ក

---

សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំដាក់បង្ហាញឯកសាររឿងក្ដី០០៣ នៅក្នុងរឿងក្ដី០០២ (ឯកសារ D100/25 និង D100/29), ១៥ កុម្ភៈ ២០១៧, កថាខណ្ឌ១៩ (ការយោងសំអាងខាងក្នុងត្រូវបានរំលងចោល)។

41 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៥១។

42 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៣។

43 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៣។

44 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៤។

45 **D309/2/1/3** ចម្លើយតប, ជើងទំព័រ៧៦។

46 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៣។

ក្នុងនាមជាស្ថាប័នយុត្តិធម៌ចំពោះភាព ‘បរាជ័យ“ក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋធ្ងន់ធ្ងរ”[47] ជាហេតុផលត្រឹមត្រូវដើម្បីរក្សា*ដីកាដំណោះស្រាយ (សំអាងហេតុ)* ទាំងមូលទុកមិនឲ្យសាធារណជនមើលនោះ។ ប្រសិនបើពួកគេអាចចូលមើល*ដីកាដំណោះស្រាយ (សំអាងហេតុ)* ទាំងមូលបាន សមាជិកមួយចំនួនក្នុងចំណោមសាធារណជនទាំងនោះអាចរិះគន់វា ខណៈដែលអ្នកផ្សេងទៀតអាចសរសើរវា។ ប៉ុន្តែទោះយ៉ាងណា តុលាការមួយរក្សាទុកព័ត៌មានមិនឱ្យសាធារណជនមើល ដោយគ្រាន់តែហេតុផលថាខ្លួនភ័យខ្លាចការរិះគន់នោះ គឺពិតជាគោលជំហរមួយគួរឲ្យបារម្ភណ៍ណាស់។ ជាងនេះទៀត ប្រសិនបើក្ដីកង្វល់អំពីការរិះគន់គឺជាមូលហេតុត្រឹមត្រូវនោះ ដូច្នេះវាពិតជាហេតុផលកាន់តែខ្លាំងទៅទៀតដែលត្រូវដកការកោសលុបទាំងនោះចេញ៖ ដូចដែលបានកត់សម្គាល់នៅក្នុងបណ្ដឹងឧទ្ធរណ៍ សាធារណជនបានរិះគន់រួចទៅហើយអំពីកង្វះខាតតម្លាភាពដែលបណ្ដាលមកពីការកោសលុបដ៏ច្រើនសន្ធឹកសន្ធាប់នៃ *ដីកាដំណោះស្រាយ (សំអាងហេតុ)*[48]។ ច្បាស់ណាស់ថា ការការពារមន្ត្រី អ.វ.ត.ក ពីការត្រួតពិនិត្យរបស់សាធារណជន ឬការរិះគន់នោះ គឺមិនមែនជាហេតុផលត្រឹមត្រូវសម្រាប់ការរក្សាការសម្ងាត់នោះទេ។

15. អ៊ឹម ចែម អះអាងថា ការកោសលុបដ៏ច្រើនសន្ធឹកសន្ធាប់មានភាពត្រឹមត្រូវ ដោយសារតែរូបគាត់ត្រូវបាន “ដកហូតនូវឱកាសដ៏មានអត្ថន័យដើម្បីធ្វើការឆ្លើយតប ឬធ្វើការតតាំងនឹងភស្តុតាងទាំងឡាយដែលកំណត់នៅក្នុងអំណះអំណាងទាំងនេះ”[49]។ ប៉ុន្តែ ការណ៍នេះបដិសេធចោលថា គាត់បានទទួលឱកាសបែបនោះរួចទៅហើយ នៅដំណាក់កាលស៊ើបអង្កេត ទាំងតាមរយៈការដាក់សំណើសុំស៊ើបសួរ និងតាមរយៈការដាក់ចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។ អ៊ឹម ចែម អះអាងថា គាត់បានដាក់កម្រិតការឆ្លើយតបរបស់គាត់ត្រឹមបញ្ហាទាក់ទងនឹងយុត្តាធិការបុគ្គល ផ្អែកលើសេចក្ដីជូនដំណឹងពី សចស ថាវាគឺជាបញ្ហគតិយុត្តសំខាន់តែមួយគត់ដែលលើកឡើងនៅក្នុងដីកាដំណោះស្រាយ[50] ប៉ុន្តែគាត់ខកខានមិនបានយល់ថាការរកឃើញផ្នែកអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មជាមូលដ្ឋានភ្ជាប់ផ្ទាល់ទៅនឹងបញ្ហាយុត្តាធិការអំពីថាតើ អ៊ឹម ចែម គឺជាបុគ្គលម្នាក់ក្នុងចំណោមជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ឬយ៉ាងណា។ ការសម្រេចនានារបស់ក្រុមការពារក្ដីរបស់គាត់ ទាក់ទងនឹងរបៀបដែលលើកឡើង

---

[47] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៥។

[48] **D309/2/1/2** បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ ១៨។

[49] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៧។

[50] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៦។

បញ្ហានោះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន មិនមែនជាមូលដ្ឋានត្រឹមត្រូវដើម្បីរក្សាទុក*ដីកាដំណោះស្រាយ (សំអាងហេតុ)* មិនឱ្យសាធារណជនចូលមើលនោះឡើយ។

16. សម្រាប់មូលហេតុដូចគ្នានេះដែរ ការណ៍ដែលថាការរកឃើញផ្នែកអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានចោទថាជាប់ទាក់ទងនឹង អ៊ឹម ចែម មានទំនាក់ទំនងផ្ទាល់ទៅនឹងបញ្ហាយុត្តាធិការអំពីថាតើ រូបគាត់គឺជាបុគ្គលម្នាក់ក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ឬយ៉ាងណា ការអះអាងរបស់ អ៊ឹម ចែម ថា ការរកឃើញរបស់ សចស អំពីឧក្រិដ្ឋកម្មទាំងឡាយនៅក្នុង*ដីកាដំណោះស្រាយ (សំអាងហេតុ)* គឺជា*ការធ្វើឡើងហួសពីសិទ្ធិអំណាច*[51]នោះក៏គ្មានន័យដែរ។ ហើយ អ៊ឹម ចែម ក៏ខុសផងដែរក្នុងការកំណត់លក្ខណៈការរកឃើញរបស់ សចស ថាជា "បណ្តោះអាសន្ន"នោះ[52]។ ទោះបីជាការរកឃើញរបស់ សចស មិនចាំបាច់ឈានទៅដល់កម្រិតនៃការបញ្ជាក់ "ហួសពីវិមតិសង្ស័យ" ដែលតម្រូវសម្រាប់ការផ្តន្ទាទោសនៅសវនាការក៏ដោយ ក៏មិនមានអ្វីបណ្តោះអាសន្នអំពីការសន្និដ្ឋានរបស់ពួកគេថា អ៊ឹម ចែម ជាឧទាហរណ៍ "បានបញ្ជាឱ្យដាក់ឱ្យទៅជាទាសករ ឃុំឃាំង និងសម្លាប់ប្រជាជននៅមន្ទីរសន្តិសុខភ្នំត្រយោង និងដាក់ពលករនៅការដ្ឋានប្រឡាយស្ពានស្រែងឱ្យទៅជាទាសករ"[53]។

17. អ៊ឹម ចែម លើកឡើងថា ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សក្នុងរឿងក្តី *Sayadi និង Vinck ទល់នឹង ប្រទេសបែលហ្ស៊ិក*[54] បង្ហាញថាមាត្រា ១៧ នៃកតិកាសញ្ញា ICCPR រួមបញ្ចូលសិទ្ធិនៃការការពារពី "ការផ្សំគំនិតអវិជ្ជមាន"[55]។ ប៉ុន្តែ រឿងក្តី *Sayadi* ពាក់ព័ន្ធនឹងការដាក់ឈ្មោះបុគ្គលនានាដោយរដ្ឋមួយនៅក្នុងបញ្ជីដែលភ្ជាប់ពួកគេទៅនឹងអំពើភេរវកម្មដោយមិនមានដំណើរការច្បាប់ត្រឹមត្រូវ[56]។ ផ្ទុយទៅវិញ អ៊ឹម ចែម ត្រូវបានតំណាងដោយស្នាក្តី និងមានឱកាសយ៉ាងទូលំទូលាយដើម្បីដាក់អំណះអំណាងរបស់ខ្លួន និងដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរទៅកាន់ សចស ដែលជា

---

51 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៦២-៦៧។

52 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៣, ៥៥។

53 **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ៣១០។

54 គណៈកម្មាធិការសិទ្ធិមនុស្ស, បណ្តឹងលេខ 1472/2006, Nabil Sayadi និង Patricia Vinck ទល់នឹង Belgium, ២២ តុលា ២០០៨។

55 **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៥៩។

56 គណៈកម្មាធិការសិទ្ធិមនុស្ស, បណ្តឹងលេខ 1472/2006, Nabil Sayadi និង Patricia Vinck ទល់នឹង Belgium, ២២ តុលា ២០០៨, កថាខណ្ឌ ២.២, ២.៣, ១០.១៣។

អង្គភាពតុលាការអព្យាក្រិត្យមួយដែលជាអ្នកស្វែងរកការពិត។ នេះគឺជាភាពខុសគ្នាដ៏សំខាន់មួយ នៅពេលដែលពិចារណាថាតើ លក្ខខណ្ឌតម្រូវរបស់ មាត្រា១៧ អំពីភាព "មិនត្រឹមត្រូវតាមច្បាប់" ទាក់ទងនឹងការជ្រៀតជ្រែកជាមួយនឹងសិទ្ធិពាក់ព័ន្ធត្រូវបានបំពេញ ឬយ៉ាងណា ដែលនៅក្នុងករណីនេះមិនដូច្នោះឡើយ។

18. ជាចុងក្រោយ ដោយខកខានមិនបានប្ដឹងឧទ្ធរណ៍ការកោសលុបនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ឲ្យបានទាន់ពេលវេលាដោយខ្លួនឯងនោះ អ៊ឹម ចែម ព្យាយាមប្រើចម្លើយតបរបស់ខ្លួន ដើម្បីធ្វើសំណើផ្ទាល់ខ្លួនឲ្យធ្វើការកែប្រែការអនុវត្តការការកោសលុបទាំងនោះ និងឲ្យធ្វើការកោសលុបនៅក្នុងកន្លែងជាច្រើន ដើម្បីកោសលុប*ដីកាដំណោះស្រាយ (សំអាងហេតុ)* បន្ថែមទៀត[57]។ គាត់ប៉ុនប៉ងកំណត់លក្ខណៈសំណើទាំងអស់នេះថាជា "ការកែសម្រួលលក្ខណៈមិនត្រឹមត្រូវនៃអក្សរដែលបោះពុម្ព" ប៉ុន្តែពួកវាមិនមែនជាការកែសម្រួលប្រភេទបែបនោះទាល់តែសោះ។ អំណះអំណាងរបស់ អ៊ឹម ចែម បង្ហាញច្បាស់ថា គាត់ជំទាស់ជាសារវ័ន្តទៅនឹងដីកាសម្រេចរបស់ សចស ដែលបានសម្រេចលើអ្វីដែលត្រូវកោសលុប។ ការប៉ុនប៉ងមិនត្រឹមត្រូវតាមពេលវេលាដើម្បីដាក់បណ្ដឹងឧទ្ធរណ៍**បែបលាក់លៀម**នេះ មិនគួរត្រូវបានអនុញ្ញាតនោះឡើយ។ ប៉ុន្តែ ទោះជាយ៉ាងណា សំណៅសាធារណៈនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* អាចរកបានជាសាធារណៈអស់រយៈពេលពីរខែមកហើយ។ ត្រង់ចំណុចនេះ វាមិនអាចទៅរួចទេដែលត្រូវលាក់បាំងផ្នែកបន្ថែមទៀតនៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ពីសាធារណជននោះ។ យ៉ាងណាក៏ដោយ វាមានតម្លៃគួរកត់សម្គាល់ថា អ៊ឹម ចែម ក្នុងការធ្វើសំណើនេះទៅកាន់អង្គបុរេជំនុំជម្រះ ពិតជាផ្ទុយទៅនឹងគោលជំហរពីមុនរបស់គាត់ដែលមិនត្រូវបានគាំទ្រតាមច្បាប់ ដែលថាការកោសលុបគឺជាការសម្រេចតាមឆន្ទានុសិទ្ធិសម្រាប់តែ សចស តែឯងប៉ុណ្ណោះ។

19. លើសពីនេះទៀត អំណះអំណាងរបស់គាត់ដែលស្នើសុំការកោសលុបបន្ថែមទៀត ពុំមានអង្គសេចក្ដីនោះទេ។ អ៊ឹម ចែម អះអាងថា "ឈ្មោះ ទុំ សឿន និង ពេជ្រ ជឹម។ ឈ្មោះទាំងពីរនេះគប្បីធ្វើការកោសលុបចេញជាដរាប"[58]។ យ៉ាងណាក៏ដោយ អ្វីដែលគាត់ចង់មានន័យដោយសន្មតនោះគឺថា ឈ្មោះរបស់ពួកគាត់ត្រូវតែកោសលុបកាលណាវាមានកើតឡើង ដូចដែលវាត្រូវបានកោសលុប "យ៉ាងជាប់លាប់" យោងទៅតាមតក្កវិជ្ជារបស់ សចសៈ វាត្រូវបានកោសលុប

---

[57] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៦៨-៧៥។

[58] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៧០។

កាលណាពួកវាត្រូវបានលើកឡើងជាប្រភពសម្រាប់ភស្តុតាង ឬមួយនៅក្នុងតួសេចក្តី ឬមួយនៅក្នុងកំណត់សម្គាល់ជើងទំព័រ និងទាំងនៅក្នុងផ្នែកទាំងឡាយនៃ*ដីកាដំណោះស្រាយ(សំអាងហេតុ)* ដែលបានពិភាក្សាពីការរកឃើញបទល្មើសព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ អ៊ឹម ចែម មិនបានផ្តល់នូវការពន្យល់ - ដ៏សមហេតុផល ឬផ្សេងពីនេះ - អំពីថាតើហេតុអ្វីបានជាគាត់ជឿជាក់ថាឈ្មោះរបស់ពួកនោះត្រូវតែបានកោសលុបកាលណាវាបានកើតឡើង ហើតវាមិនមានអ្វីទាល់តែសោះ។

20. អ៊ឹម ចែម ខកខានមិនបានផ្តល់នូវអំណះអំណាងណាមួយដូចគ្នានេះដែរ នៅក្នុងការគាំទ្រនូវសេចក្តីអះអាងរបស់គាត់ដែលថា ផ្នែក៤.៤ នៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ត្រូវតែបានកោសលុបពីព្រោះវាជា "ព័ត៌មានសម្ងាត់ទាក់ទងទៅនឹងភស្តុតាង មិនមែនជា "សេចក្តីសន្និដ្ឋានលើអង្គច្បាប់សំខាន់ៗ" ទេ"[59]។ សូម្បីតែយោងទៅតាម អ៊ឹម ចែម ការយល់ឃើញផ្នែកច្បាប់ដ៏សំខាន់ នៃ *ដីកាដំណោះស្រាយ (សំអាងហេតុ)* គឺជាបញ្ហាថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ថាជាម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។ ដោយសារផ្នែក ៤.៤ បានលើកឡើងពី "តួនាទី និងសិទ្ធិអំណាចរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគពាយ័ព្យ" ការអះអាងដែលថាវាមិនពាក់ព័ន្ធទៅនឹង "ការយល់ឃើញផ្នែកច្បាប់ដ៏សំខាន់" គឺមិនគាំទ្រនោះទេ។

21. អ៊ឹម ចែម ក៏បានស្វែងរកផងដែរនូវការកោសលុបលើការលើកឡើងទៅនឹងសេចក្តីថ្លែងរបស់គាត់ដែលបានធ្វើឡើងនៅខាងក្រៅអង្គការ រួមទាំង DC-Cam ផងដែរ[60]។ គាត់យកជាមូលដ្ឋាននៅលើសំណើនេះគឺ សិទ្ធិរបស់គាត់ដែលមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយបានបង្កប់ន័យថា វាជាការព្រួយបារម្ភអំពីសិទ្ធិនេះដែលបាននាំឲ្យ សចស ដាក់ទម្ងន់តិចតួចទៅលើសេចក្តីថ្លែងទាំងនេះ ជាជាងទៅលើការស្តាប់ចម្លើយនានាដែលបានធ្វើឡើងដោយ កសចស។ ប៉ុន្តែការលើកទឹកចិត្តបែបដូច្នេះ មិនមែនជាភស្តុតាងនៅក្នុងកថាខណ្ឌដែលបានលើកឡើងនោះទេ - ឬកថាខណ្ឌផ្សេងៗទៀត - នៃ*ដីកាដំណោះស្រាយ (សំអាងហេតុ)* ដែលគ្រាន់តែបានពន្យល់ថាមានទម្ងន់តិចតួចជាងការផ្តល់ទៅឲ្យសេចក្តីថ្លែងនានានៅខាងក្រៅ "ស្របជាមួយនឹងវិធីសាស្ត្រដែលបានអនុវត្តនៅក្នុងសំណុំរឿង០០២ និងវិធានទូទៅនៃការវាយតម្លៃលើភស្តុតាងដែលបានពន្យល់នៅក្នុងផ្នែកនេះ"[61]។ វិធានទូទៅទាំងនោះស្តីពីការវាយតម្លៃលើភស្តុតាង បានពន្យល់ថា សចស

[59] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ៧០។

[60] **D309/2/1/3** ចម្លើយតប, កថាខណ្ឌ ៧៣-៧៥។

[61] **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ១៣៩។

បានផ្តល់ទម្ងន់តិចតួចទៅនឹងសេចក្តីថ្លែងនានាដែលបានផ្តល់ឱ្យនៅខាងក្រៅអង្គភាព មិនមែនពីព្រោះតែការព្រួយបារម្ភដែលពាក់ព័ន្ធនឹងការប្រឆាំងនឹងខ្លួនឯង ប៉ុន្តែពីព្រោះតែ "ការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយមិនមានការធានាតាមផ្លូវតុលាការ និងទម្រង់ដែលកំណត់លក្ខណៈនៃកំណត់ហេតុស្តាប់ចម្លើយ នោះឡើយ"[62]។ បន្ថែមលើនេះ វាគួរតែច្បាស់ក្រឡែតថា សេចក្តីថ្លែង**ដោយស្ម័គ្រចិត្ត** របស់ អ៊ឹម ចែម ដែលបានធ្វើឡើងទៅកាន់អង្គភាពខាងក្រៅនានា មិនរំលោភលើសិទ្ធិរបស់គាត់ប្រឆាំងនឹងខ្លួនឯង**ដោយបង្ខិតបង្ខំ**ទាល់តែសោះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature and seal] |

[62] **D308/3** ដីកាដំណោះស្រាយ(សំអាងហេតុ), កថាខណ្ឌ១០៤។